# មេរៀន៤ ៖ កម្រិតផ្សេងៗគ្នានៃអត្តសញ្ញាណកម្ម

## Lesson4: Different Level of Identity

# ការអប់រំភាពជាពលរដ្ឋសកល

បទបង្ហាញដោយ៖ **ល. ឌី មុន្នា** - NIE





# មាតិកា

១. អត្ថន័យនៃអត្តសញ្ញាណកម្ម

២. អត្តសញ្ញាណបុគ្គល

៣. ការបង្កើតអត្តសញ្ញាណកម្ម

# វត្ថុបំណង

- រៀបចំសម្របខ្លួនក្នុងសហគមន៍ សង្គមជាតិ និងធ្វើអន្តរកម្មខ្លួនតាមរយៈការអភិវឌ្ឍជំនាញទំនាក់ទំនងអន្តរបុគ្គល
- ពិនិត្យពីកម្រិតខុសគ្នានៃអត្តសញ្ញាណនិងភាពជាប់ពាក់ព័ន្ធលើទំនាក់ទំនងជាមួយអ្នកដទៃ
- បែងចែកពីភាពខុសគ្នារវាងអត្តសញ្ញាណកម្មបុគ្គល អត្តសញ្ញាណកម្មរួម ក្រុមមនុស្សផ្សេងៗគ្នា និងបណ្តុះសតិស្មារតីឱ្យយល់ពីតម្លៃទៅលើមនុស្សជាតិទូទៅ
- កំណត់មធ្យោបាយនៃកម្រិតខុសគ្នារបស់អត្តសញ្ញាណ ដែលអាចមានអន្តរកម្មគ្នាទៅវិញទៅមកក្នុងការរស់នៅប្រកបដោយសន្តិភាពជាមួយក្រុមមនុស្សផ្សេងៗគ្នា។

# ១. អត្ថន័យអត្តសញ្ញាណកម្ម

ជាសតិអារម្មណ៍ផ្ទាល់របស់បុគ្គលម្នាក់ៗ ដែលបង្កើតឡើងដោយចរិតលក្ខណៈពិសេសផ្សារភ្ជាប់ទាក់ទងគ្នាជាមួយតួនាទីក្នុងក្រុម សហគមន៍ ឬ ក្នុងសង្គម ។

. មាននិរន្តភាព ដោយមនុស្សម្នាក់ៗមានគំនិតទស្សនៈសតិអារម្មណ៍ស្រដៀងគ្នាទៅនឹងមនុស្សឬក្រុមផ្សេងទៀត ហើយបន្តិចម្តងៗក្លាយជាមនុស្សឬក្នុងក្រុមតែមួយ ទោះជាមានការផ្លាស់ប្តូរច្រើនគ្រប់រូបភាពឬស្ថានភាពយ៉ាងណាក៏ដោយ។

. ឆ្លុះបញ្ចាំងពីផ្នាត់ចិត្តគំនិផ្ទាល់ខ្លួនរបស់មនុស្សម្នាក់ៗដោយបានបង្កើតចរឹតលក្ខណៈពិសេសផ្សារភ្ជាប់គ្នានឹងតួនាទីក្នុងបរិបទសង្គម។

# តើអត្តញ្ញាណកម្មភាពជាពលរដ្ឋសកលមានន័យដូចម្តេច?

**ការអប់រំពលរដ្ឋសកល**(GCED)៖ ការបង្ហាញនូវសិទ្ធអំណាចរបស់អ្នកសិក្សាទាំងអស់ឱ្យមាននាទីសំខាន់ៗទាំងក្នុងសហគមន៍(locally)និងក្នុងបរិបទសកល(globally)ដើម្បីកសាងសន្តិភាព ចេះសណ្ដោសប្រណី ឬ មានមោទនៈភាព(tolarant) បរិយាបន្ន និងសុវត្ថិភាពសង្គម ដោយផ្អែកលើទស្សនៈទានចំនួនបីរួមមាន៖ ពុទ្ធិ(cognitive) ចិត្តលក្ខណៈ និង ចរិយាមាយាទ ។




**ពាក្យគន្លឹះ៖**

## សន្តិភាព និង និរន្តរភាព

# ២. អត្តសញ្ញាណកម្មបុគ្គល

. ជាបណ្តុំនៃជំនឿ និងគំនិតទស្សនៈដែលបុគ្គលនោះមានក្នុងខ្លួនផ្ទាល់។ បណ្តុំនៃគោលគំនិតឬក៏ជាអត្តសញ្ញាណបុគ្គលជាការបញ្ចូលរួមគ្នារាងកាយវិទ្យា ចិត្តវិទ្យា និងសង្គមវិទ្យា ដែលអាចទទួលឥទ្ធិពលពីឥរិយាបថ ទម្លាប់ ជំនឿ និងគំនិតទស្សនៈរបស់បុគ្គល។

. មានច្រើនប្រភេទស្ថិតក្នុងបុគ្គលម្នាក់ៗរួមគ្នា ដូចជាអត្តសញ្ញាណកម្ម៖

- វប្បធម៌
- វិជ្ជាជីវៈ
- ជនជាតិ  សញ្ជាតិ សាសនា ជំនឿ និង
- យេនឌ័រ ជាដើម( ចរិតនិងបុគ្គលិកលក្ខណៈរួមគ្នាឬដូចគ្នា ) ។

# ២. អត្តសញ្ញាណកម្មបុគ្គល

កម្រិតផ្សេងៗនៃការផ្លាស់ប្តូរតាមវ័យ

១ វ័យកុមារភាព

២ វ័យជំទង់

៣ ពេញវ័យ ( កណ្តាល )

៤ វ័យចំណាស់

# ២. អត្តសញ្ញាណកម្មបុគ្គល

៤

១

កម្រិតផ្សេងៗនៃការផ្លាស់ប្តូរតាមវ័យ

៣

២

## វ័យកុមារភាព

មានការទទួលនូវឥទ្ធិពលច្រើន ៖

. អ្នកថែទាំ មាតាបិតា ឬ អាណាព្យាបាល ជីដូនជីតា ពូមីង

. អ្នកនៅជុំវិញខ្លួន មាន៖ បងប្អូន អ្នកជិតខាង តាមរយៈ

. ការស្តាប់ ការមើលឃើញ ការលេងជាមួយ ...

. ការផ្លាស់ប្តូរមានការប្រែប្រួលបន្តិចម្តងៗនៅពេលពួកគេកាន់តែធំធាត់ឡើង

. រៀនស្តាប់ រៀនយល់ រៀនទទួលស្គាល់ រៀនបដិសេធនូវទិដ្ឋភាពផ្សេងៗ

# ២. អត្តសញ្ញាណកម្មបុគ្គល

១

២

កម្រិតផ្សេងៗនៃការផ្លាស់ប្តូរតាមវ័យ

៤

៣

## វ័យជំទង់




ក្នុងវ័យនេះការទទួលរងឥទ្ធិពលកាន់តែច្រើន ៖

. មាតាបិតាឬអាណាព្យាបាលកាន់តែតិចទៅៗ

. អ្នកនៅជុំវិញខ្លួនមាន៖ បងប្អូន អ្នកជិតខាង មិត្តភ័ក្រ សហគមន៍ សង្គមជាតិ

ចេះគិតពិចារណាតាមរយៈការសិក្សា បទពិសោធ ផ្លាស់ប្តូរផ្នត់គំនិត ទស្សនៈ និងអត្តចរិក ដើម្បីឆ្ពោះរកឯករាជ្យភាព



. អាចអភិវឌ្ឍតម្លៃ និងបំណិនពួកគេ ដែលចូលរួមសកម្មក្នុងសន្តិភាព សាមគ្គីភាព ការសម្របសម្រួល ការដោះស្រោផលប៉ះពាល់...

# ២. អត្តសញ្ញាណកម្មបុគ្គល

ភាពពេញវ

យ

. ទទួលរងឥទ្ធិពលតិចតួចពីមាតាបិតាឬអាណាព្យាបាល

. អន្តរកម្មច្រើនជាមួយ សហគមន៍ សង្គមជាតិ ពលរដ្ឋសកល គំនិតទស្សនៈទូលាយ

. ឋិតនៅក្នុងលក្ខណៈភាពជាសកលច្រើន អាចបង្កើតគោលគំនិតផ្ទាល់ខ្លួនមួយបានរឹងមាំ និងអាចអភិវឌ្ឍក្នុងទិសដៅជីវិតពួកគេបាន ដែលអាស្រ័យដោយវប្បធម៌ សេដ្ឋកិច្ច នយោបាយ ឬ បរិបទសង្គម

. តែងតែឱ្យតម្លៃ និងការពារសិទ្ធសេរីភាពរបស់ពួកគេ

. អាចបង្កើតគោលគំនិតផ្ទាល់ខ្លួនរបស់មួយរឹងមាំ ដែលអាចកំណត់ទិសដៅជីវិតខ្លួនគេ

២

៣

កម្រិតផ្សេងៗនៃការផ្លាស់ប្តូរតាមវ័យ

១

៤

# ២. អត្តសញ្ញាណកម្មបុគ្គល

៣

៤

កម្រិតផ្សេងៗនៃការផ្លាស់ប្តូរតាមវ័យ

២

១

## វ័យចំណាស់

. ទទួលឥទ្ធិពលច្រើនពីសង្គមជាតិ

. ស្ថានភាពនានាជាលក្ខណៈសកល ជាមួយ និងបទពិសោធ

. ការផ្លាស់ប្តូរអត្តសញ្ញាណកម្មមានអន្តរកម្មតិចតួច

. ផ្នត់គំនិតមានការផ្លាស់ប្តូរតិចតួចហើយមានភាពរឹងមាំទៅលើទស្សនៈរបស់ខ្លួន




ដូចក្នុងរូបភាពនេះ ជាទស្សនៈរបស់អ្នក។

តើអ្នកត្រូវនិយាយទៅកាន់ក្រុមគ្រួសារឬក្មួយរបស់អ្នកយ៉ាងដូចម្តេច ?

# ការបណ្តុះទម្លាប់ឬវប្បធម៌

ស្គាល់ → យល់ដឹង → ស្រឡាញ់ → ថែរក្សា ការពារ → ចូលរួម → ឱ្យតម្លៃ → មានទម្លាប់/វប្បធម៌

# សំណួរពិភាក្សា

១. តើត្រូវបណ្ដុះផ្នត់គំនិតសិស្សឱ្យចូលចិត្តអានយ៉ាងដូចម្ដេច ?

២. តើអ្នកត្រូវធ្វើយ៉ាងដូចម្ដេចដើម្បីឱ្យសិស្សមានទំនាប់ស្វ័យសិក្សា ?

៣. តើអ្នកត្រូវបណ្ដុះការចូលរួមសិស្សយ៉ាងដូចម្ដេចដើម្បីឱ្យបរិស្ថានសាលាស្អាត ?

៤. តើអ្នកត្រូវបណ្ដុះផ្នត់គំនិតសិស្សឱ្យសាមគ្គីគ្នាបានយ៉ាងដូចម្ដេច

៥.តើអ្នកត្រូវរៀបចំសកម្មភាពបង្រៀនក្នុងថ្នាក់យ៉ាងដូចម្ដេច ដើម្បីបណ្ដុះអត្តសញ្ញាណសិស្សចេះ ឱ្យតម្លៃលើការសិក្សា ?

# ៣. ការបង្កើតអត្តសញ្ញាណកម្ម

ការកកើតអត្តសញ្ញាណកម្មអាស្រ័យលើការទទួលបានឱកាស និងលទ្ធភាពផ្សេងៗគ្នាក្នុងជីវិត ដើម្បីធ្វើការសម្រេចចិត្តរបស់ខ្លួន។(ល.ជេហ្វ្រី អានេនេត)

**សេចក្តីស្រឡាញ់** ៖ សំដៅទៅរកភាពស្និតស្នាល ដើម្បីស្វែងរកភាពពេញចិត្តជាមួយគ្នា ទាំងលក្ខណៈជាដៃគូរ ជាក្រុម ជាសហគមន៍ ឬ ក្នុងសង្គមជាតិទាំងមូល ក្នុងការកសាងអត្តសញ្ញណរួម។

២. តើខ្ញុំចង់បានមនុស្ស...

**ឱកាសការងារ**៖ពេលវេលាសមស្របដែលពួកគេកំពុងធ្វើ ជាលក្ខខណ្ឌសមស្របមួយក្នុងការរៀបចំ និងប្រមូលផ្តុំចិត្តគំនិត ទស្សនៈ កំណត់ភាពរឹងមាំអត្តសញ្ញាណរបស់ពួកគេ។

**ទិដ្ឋភាពសកល** ៖ ជាដំណាក់កាលដែលពួកគេអាចបិតកម្រិតឧត្តមសិក្សាឬទិដ្ឋភាពខាងក្រៅនានាក្នុងការរស់នៅដែលអាចឱ្យពួកគេផ្លាស់ប្តូរទៅជាទស្សនៈសកលក្នុងការសម្រេចនូវចិត្តភាពជឿជាក់ និងគុណតម្លៃ។

# ភាពទទួលរងឥទ្ធិពលលើអត្តសញ្ញាណកម្ម

១. ឥទ្ធិពលនៃការគិតស៊ីជម្រៅ

២. ឥទ្ធិពលនៃការសិក្សា

៣. ឥទ្ធិពលនៃសង្គមវប្បធម៌

៤. ឥទ្ធិពលរបស់ឪពុកម្តាយ

៥. សង្គមតាមប្រព័ន្ធអនឡាញ និងអ៊ីនធឺណែត ...

# សេចក្តីសន្និដ្ឋាន

- អ្នកសិក្សាដែលជាពលរដ្ឋទូទៅ យល់ដឹងពីការកំណត់អត្តសញ្ញាណរបស់ពួកគេក្នុងការចូលចំណែកកិច្ចការសង្គមជាតិ ។
- ចំណេះដឹងអំពីអត្តសញ្ញាណកម្ម មានសារៈសំខាន់ក្នុងការបង្កើតអត្តសញ្ញាណរបស់ពួកក្នុងសហគមន៍ ដោយគិតពីអ្វីដែលអាចមានកម្រិតនៃអត្តសញ្ញាណកម្មខុសៗគ្នានៅក្នុងសង្គមនីមួយៗដើម្បីការរស់នៅជាមួយគ្នាប្រកបដោយសន្តិភាព។
- ការដឹងអំពីអត្តសញ្ញាណកម្មនេះ ធ្វើឱ្យពួកគេចេះរៀនសូត្រពីគ្នា និងឱ្យតម្លៃពីអត្តសញ្ញាណកម្មរវាងគ្នាទៅវិញទៅមក។ ជាលទ្ធផលពួកគេអាចរស់នៅជាមួយគ្នាប្រកបដោយភាពសុខដុមរមនាមានសន្តិភាព និងនិរន្តភាព ព្រមទាំងអាចផ្លាស់ប្តូរទស្សនៈទៅវិញទៅមកដើម្បីប្រែក្លាយខ្លួន**ភាពពលរដ្ឋសាកល**។

# អរគុណ !

